# សត្វចាបយំចេប



ចាប



ទន្សាយ



ទន្សោង



ក្ដាន់



ក្ដាម

សត្វចាបយំចេបទំដើមច័ន
សត្វក្ដាន់បោលក្ជួងទៅចូលរូងក្ដាម
ទន្សោងទន្សាយផាយចូលតាម
ត្រូវក្ដាមកៀបក បញ្ឈរភ្នែកស្ញឹង។



ទទា



សិង្ហ



សេះ

សត្វទទាដើរទទឹងទួល
ទឹកមុខបែបមិនស្រួលព្រោះឃើញសត្វសិង្ហ
សត្វសេះលេចអាចម៍មិនបាច់ប្រឹង
ស្ទន់បាត់ព្រលឹងឃើញសិង្ហដើរតាម។



កណ្ដុរ



ទីទុយ

សត្វកណ្ដុរត្បុលក្រោមកណ្ដាប់
តែភ្ញាត់ចំណាប់ត្រូវកណ្ដាប់កិនលើ
ទីទុយអង្គុយងោកលើចុងឈើ
ផ្ញើក្បាលងើងើភ្នែកឡិងឡង់។



ទុង



ទា



ត្រដក់

សត្វទុងខឹងនឹងសត្វទា
ថាបងប្អូនគ្នាម្ដេចមិនចែកទ្រព្យផង
ត្រដក់ខំត្រដរដើរកោងខ្នង
ថាអស់សត្វផងកុំទាស់ទែងគ្នា៕

សិល្បករ៖ កុល សែម

Khmer Story Lovers